ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

TONLE SAP AUTHORITY

លេខ :...២៣៦......អទស

# សេចក្តីសម្រេច

## ស្តីពីការបែងចែកសមាសភាពក្រុមការងារ ចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ)

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួល មាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ ហិកតាស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ)
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

## ស ម្រេ ច

**ប្រការ ១ ៖** ត្រូវបានបែងចែកសមាសភាពក្រុមការងារចុះតាមដានពិនិត្យ និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ) ដែលមានសមាសភាពដូចខាងក្រោម ៖

**ក- ក្រុមការងារទទួលបន្ទុកការងារក្តាប់រួម**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម **ហ៊ើល តូនី** | | អនុប្រធានក្តាប់រួម អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- ឯកឧត្តម **សរ** | **គឹមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៣- ឯកឧត្តម **ខូច** | **មាស** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៤- ឯកឧត្តម **ជា** | **សុខនី** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៥- លោក | **ហេង** | **សុវណ្ណារ៉ា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៦- លោក | **ទិន** | **ប៊ុនពៅ** | ប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៧- លោក | **យ៉ាន់** | **សំរិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | សមាជិក |
| ៨- លោក | **ហេង** | **បូរាណា** | មន្ត្រីបច្ចេកទេស | សមាជិកអចិន្ត្រៃយ៍ |

**ក្រុមការងារទទួលបន្ទុកការងារក្តាប់រួមនេះ មានភារៈកិច្ចដូចខាងក្រោម ៖**

- ដឹកនាំ តាមដានត្រួតពិនិត្យ និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- ប្រមូលផ្តុំ និងវិភាគទិន្នន័យ ដើម្បីរៀបចំផែនទី និងឯកសារបច្ចេកទេសពាក់ព័ន្ធលើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹកក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- រៀបចំរបាយការណ៍ ស្តីពីលទ្ធផលការងារ និងការវិភាគលើការតាមដានត្រួតពិនិត្យ និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ជូនឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប
- របាយការណ៍វឌ្ឍនភាពការងារជាប្រចាំជូនថ្នាក់ដឹកនាំ អាជ្ញាធរទន្លេសាប
- អនុវត្តការងារផ្សេងៗទៀត ដែលឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប ប្រគល់ជូន ។

**ខ- ក្រុមការងារទទួលបន្ទុកប្រចាំមុខព្រួញខេត្តកំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ**

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **ខូវ** | **មាស** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- លោក | **ហេង** | **សុវណ្ណារ៉ា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | អនុប្រធាន |
| ៣- លោក | **ស្រ៊ុន** | **ស៊ីលីន** | អនុប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | អនុប្រធាន |
| ៤- លោក | **លឹម** | **វុទ្ធី** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៥- លោក | **អ៊ូ** | **ទូច** | ប្រធានការិល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ | សមាជិក |
| ៦- លោក | **សុខ** | **វ៉ាយ៉ុង** | ប្រធានការិយាល័យអភិរក្ស | សមាជិក |
| ៧- លោក | **ឃាន** | **ច័ន្ទតារា** | អនុប្រធានការិយាល័យព័ត៌មានភូមិសាស្រ្ត និងផែនទី | សមាជិក |
| ៨- លោក | **ព្រហ្ម** | **សុគំនិត** | អនុប្រធានការិល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ | សមាជិក |

**ក្រុមការងារទទួលបន្ទុកប្រចាំមុខព្រួញខាងលើនេះ មានភារកិច្ចដូចខាងក្រោម ៖**

- តាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់និយាមកាបង្គោលព្រំការពារដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងភូមិសាស្រ្តខេត្តកំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ
- សហការសម្របសម្រួលជាមួយក្រសួងស្ថាប័នជំនាញ និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីចុះអធិការកិច្ចលើរាល់គ្រប់សកម្មភាពពាក់ព័ន្ធដែនព្រៃលិចទឹក និងព្រៃលិចទឹកក្នុងភូមិសាស្រ្តខេត្តកំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ
- លើកសំណើសុំជួសជុល ថែទាំ ឬដាំបង្គោលព្រំ និងស្លាកសញ្ញាការពារដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងភូមិសាស្រ្តខេត្តកំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ
- របាយការណ៍ពីសកម្មភាពការងារជាប្រចាំ បញ្ជូនព័ត៌មានទិន្នន័យ និងរៀបចំរបាយការណ៍ ស្តីពីលទ្ធផលការងារចុះអនុវត្ត ជូនមកក្រុមការងារទទួលបន្ទុកការងារក្តាប់រួមខាងលើ
- អនុវត្តការងារផ្សេងៗទៀត ដែលឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប ប្រគល់ជូន ។

**គ- ក្រុមការងារទទួលបន្ទុកប្រចាំមុខព្រួញខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង**

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **ជា** | **សុខនី** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- លោក | **ទិន** | **ប៊ុនពៅ** | ប្រធាននាយកដ្ឋានធនធានធម្មជាតិ | អនុប្រធាន |
| ៣- លោក | **ប៉ុន** | **វុឌ្ឍី** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | អនុប្រធាន |
| ៤- លោក | **ខ្វាន់** | **តក្រា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៥- លោក | **ខូវ** | **វេងសុខ** | ប្រធានការិយាល័យធនធានរ៉ែ | សមាជិក |
| ៦- លោក | **ម៉ម** | **សុធា** | ប្រធានការិល័យជីវចម្រុះ | សមាជិក |
| ៧- លោក | **ឡុញ** | **ណារិន្ទ** | ប្រធានការិយាល័យកសិកម្មចម្រុះ | សមាជិក |
| ៨- លោក | **អ៊ុំ** | **ពុទ្ធាលី** | អនុប្រធានការិល័យធនធានទឹក | សមាជិក |

ក្រុមការងារទទួលបន្ទុកប្រចាំមុខព្រួញខាងលើនេះ មានភារកិច្ចដូចខាងក្រោម ៖

- តាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់និយាមកាបង្គោលព្រំការពារដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង
- សហការសម្របសម្រួលជាមួយក្រសួងស្ថាប័នជំនាញ និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីចុះអធិការកិច្ចលើរាល់គ្រប់សកម្មភាពពាក់ព័ន្ធដែនព្រៃលិចទឹក និងព្រៃលិចទឹកក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង
- លើកសំណើសុំជួសជុល ថែទាំ ឬដាំបង្គោលព្រំ និងស្លាកសញ្ញាការពារដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង
- រាយការណ៍ពីសកម្មភាពការងារជាប្រចាំ បញ្ជូនព័ត៌មានទិន្នន័យ និងរៀបចំរបាយការណ៍ ស្ដីពីលទ្ធផលការងារចុះអនុវត្ត ជូនមកក្រុមការងារទទួលបន្ទុកការងារក្ដាប់រួមខាងលើ
- អនុវត្តការងារផ្សេងៗទៀត ដែលឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប ប្រគល់ជូន ។

**ឃ- ក្រុមការងារទទួលបន្ទុកផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្ត ព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សរ គឹមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- លោក | **យ៉ាន់ សំរិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | អនុប្រធាន |
| ៣- លោក | **លឹម ហេង** | អនុប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | អនុប្រធាន |
| ៤- លោក | **អ៊ុល សុជាតិ** | ប្រធានការិយាល័យសម្របសម្រួលវិវាទ | សមាជិក |
| ៥- លោក | **ទូច សំណាង** | ប្រធានការិយាល័យផ្សព្វផ្សាយ | សមាជិក |
| ៦- លោក | **សុខ មុនី** | ប្រធានការិយាល័យនីតិកម្ម | សមាជិក |
| ៧- លោក | **ផូ សំណាង** | អនុប្រធានការិយាល័យបុគ្គលិក និងបណ្ដុះបណ្ដាល | សមាជិក |
| ៨- លោក | **អ៊ុំចចំរើន រង្សី** | អនុប្រធានការិយាល័យផែនការ និងសហប្រតិបត្តិការ | សមាជិក |
| ៩- លោក | **លួង គឹមលុយ** | អនុប្រធានការិយាល័យសម្របសម្រួលវិវាទ | សមាជិក |

ក្រុមការងារទទួលបន្ទុកផ្សព្វផ្សាយខាងលើនេះ មានភារកិច្ចដូចខាងក្រោម ៖

- ស្រាវជ្រាវ និងប្រមូលផ្ដុំចងក្រងឯកសារច្បាប់ បទដ្ឋានគតិយុត្ត និងព័ត៌មាន ដែលពាក់ព័ន្ធការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក ជីវចម្រុះ និងព្រៃលិចទឹកនៅតំបន់ជុំវិញបឹងទន្លេសាប
- សហការសម្របសម្រួលជាមួយក្រសួងស្ថាប័នជំនាញ និងអាជ្ញាធរដែនដី ដើម្បីផ្សព្វផ្សាយច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មាន និងចំណេះដឹង ដល់ប្រជាពលរដ្ឋ និងសហគមន៍នៅតំបន់ជុំវិញបឹងទន្លេសាប
- រាយការណ៍ពីសកម្មភាពការងារជាប្រចាំ និងរៀបចំរបាយការណ៍ ស្ដីពីលទ្ធផលការងារចុះអនុវត្ត ជូនក្រុមការងារទទួលបន្ទុកការងារក្ដាប់រួមខាងលើ
- អនុវត្តការងារផ្សេងៗទៀត ដែលឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន ។

**ប្រការ ២ ៖** ក្រុមការងារទាំង ៤ នេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទ អ.ទ.ស ឲ្យជួយការងារទៅតាមការចាំបាច់ ។

**ប្រការ ៣ ៖** អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានគ្រប់នាយកដ្ឋានចំណុះឲ្យអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប និងសាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ចន្ទ ៣ រោច ខែ ភទ្របទ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រី**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**ចៅ_ជេដ្ឋា**

**ចម្លងជូន៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- រដ្ឋបាលខេត្តពាក់ព័ន្ធទាំង ៦
- ដូចក្នុងប្រការ ៣
- ឯកសារ កាលប្បវត្តិ